វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

The NGO Forum on Cambodia

ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង

*Working Together for Positive Change*

# កំណត់ហេតុ

# កិច្ចប្រជុំសមាជិកប្រចាំឆ្នាំ




ថ្ងៃសុក្រ ទី២៦ ខែមេសា ឆ្នាំ២០១៣

មជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-ជប៉ុន (CJCC)

# កំណត់ហេតុ
# កិច្ចប្រជុំសមាជិកប្រចាំត្រីមាស
## វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

ថ្ងៃសុក្រ ទី២៦ ខែមេសា ឆ្នាំ២០១៣ វេលាម៉ោង ០៨ព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់

ទីកន្លែង: មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការ កម្ពុជា-ជប៉ុន (CJCC)
អាគារ IFL, មហាវិថីសហពន្ធ័រុស្ស៊ី, រាជធានីភ្នំពេញ

៚✵៙

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានរៀបចំកិច្ចប្រជុំសមាជិកប្រចាំត្រីមាសជាលើកទីពីររបស់ខ្លួនក្នុងឆ្នាំ២០១៣ ដែលបានប្រព្រឹត្តទៅ នៅថ្ងៃសុក្រ ទី២៦ ខែមេសា ឆ្នាំ២០១៣ នៅសាលប្រជុំនៃមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការ កម្ពុជា-ជប៉ុន (CJCC)។ កិច្ចប្រជុំបានចាប់ផ្តើម នៅម៉ោង ០៨ ព្រឹក និងបញ្ចប់នៅម៉ោង ១២ ថ្ងៃត្រង់ ដែលមានអ្នកចូលរួមសរុបចំនួន ១៤៥ នាក់ (ក្នុងនោះមានស្ត្រី ៥០ នាក់) មកពីខេត្ត-ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ដែលជាតំណាងមកពីអង្គការសមាជិក តំណាងអង្គការសង្គមស៊ីវិល និងសមាជិកបណ្តាញ របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។

### ១. មតិស្វាគមន៍របស់ប្រធានអង្គប្រជុំ



**លោក ស៊ុន យ៉ា** នាយកប្រតិបត្តិ នៃអង្គការភូមិខ្ញុំ និងជាសមាជិកគណៈកម្មាធិការគ្រប់គ្រង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានដឹកនាំការប្រជុំ និងចាប់ផ្តើមការប្រជុំដោយបានជម្រាបជូនអង្គប្រជុំអំពីការចូលរួមរបស់សមាជិកបណ្តាញ ដែលមានសមាជិកប្រមាណ ៣០០ អង្គការ ហើយបានចូលរួមជួយរៀបចំផែនការយុទ្ធសាស្ត្រពីឆ្នាំ ២០១៤-២០១៨។ លើសពីនេះទៀត លោកបានសង្ខេបជូនអំពីលទ្ធផលរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ដែលរួមមាន ការពិគ្រោះយោបល់ជាសាធារណៈស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដីកសិកម្ម និងការពិគ្រោះយោបល់ និងគាំទ្រគោលនយោបាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ សម្រាប់ត្រីមាសបន្ទាប់ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា រួមទាំងសមាជិក នឹងរៀបចំការពិគ្រោះ យោបល់គោលនយោបាយស្តីពីផែនការយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល ហើយក៏ត្រូវការគាំទ្រ និងចូលរួមពីសមាជិកផងដែរ។ ចំពោះការប្រជុំនាថ្ងៃនេះ នឹងមានការពិភាក្សាផងដែរលើប្រធានបទមួយចំនួន ដូចជា ក) គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍បៃតង ខ) ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍន៍បៃតង ២០១៣-២០៣០ និង គ) ការអភិវឌ្ឍន៍បៃតង និងសេចក្តីព្រៀងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ វាគ្មិនសម្រាប់ការប្រជុំថ្ងៃនេះ រួមមានដូចខាងក្រោម:

- **ឯកឧត្តមបណ្ឌិត ឈុន វណ្ណៈ** អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍបៃតង នៃក្រសួងបរិស្ថាន - គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍បៃតង និងផែនការយុទ្ធសាស្រ្តជាតិស្តីពីការអភិវឌ្ឍន៍បៃតង ឆ្នាំ ២០១៣-២០៣០។
- **លោកបណ្ឌិត តាន់ មុនីវណ្ណ** អគ្គនាយករងនៃក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប - បទពិសោធន៍នៃការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍បៃតងនៅក្នុងប្រទេសកម្ពុជា។
- **លោក តឹក វណ្ណារ៉ា** នាយកប្រតិបត្តិរង ទទួលបន្ទុកកម្មវិធី វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា - ទស្សនៈរបស់អង្គការសង្គមស៊ីវិលចំពោះការអភិវឌ្ឍន៍បៃតង។
- **លោក ឈិត សំអាត** នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា - ចែករំលែក លទ្ធផលនៃការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលរៀបចំឡើងដោយអង្គការសង្គមស៊ីវិល ឬ EIA។
- **លោកស្រី ញឹម ប៉ូរ៉ានី** តំណាងសហគមន៍ខេត្តរតនគិរី - បទពិសោធន៍នៃសហគមន៍រងគ្រោះចំពោះដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។
- **លោកស្រី ចាន់ សុខយ៉េង** ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា - បច្ចុប្បន្នកម្មព័ត៌មាននៃដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ និងវេទិកាពិភាក្សាស្តីអំពីគោលនយោបាយ។

## ២. សកម្មភាព និងលទ្ធផលនៃការប្រជុំ

### ២.១ បទបង្ហាញអំពីគោលនយោបាយជាតិស្តីពីផែនការអភិវឌ្ឍន៍បៃតង និងផែនការយុទ្ធសាស្រ្តស្តីពីការអភិវឌ្ឍន៍បៃតង ២០១៣-២០៣០:

**ឯកឧត្តមបណ្ឌិត ឈុន វណ្ណៈ** អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍបៃតង នៃក្រសួងបរិស្ថាន បានធ្វើបទបង្ហាញលើប្រធានបទចំនួន ០៣ សំខាន់ៗ រួមមានលំអិតដូចខាងក្រោមៈ

- **ទស្សនទាននៃការអភិវឌ្ឍន៍បៃតងៈ** គឺដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រទេស និងធ្វើឲ្យប្រសើរឡើង និងធានាបាននូវសមធម៌, ការទំនាក់ទំនងគ្រប់វិស័យ និងធានានូវតុល្យភាពនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងប្រទេសកម្ពុជា។ លើសពីនេះទៅទៀត ការអភិវឌ្ឍន៍បៃតងមានន័យថា ជម្រុញឲ្យមានការប្រើប្រាស់កាបូនតិច និងរួមចំណែកដល់ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ យ៉ាងណាក៏ដោយ ការអភិវឌ្ឍន៍នេះ ត្រូវការចំណេះដឹង, ការអប់រំផ្សព្វផ្សាយទៅគ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅទូទាំងប្រទេស។ ជាបន្ថែម ការអភិវឌ្ឍនេះនឹងជម្រុញឲ្យមានកិច្ចសហប្រតិបត្តិការជាលក្ខណៈទ្វេរភាគី និងពហុភាគីផងដែរ។ យ៉ាងនេះក្តី ចំនុចសំខាន់នៃការអភិវឌ្ឍន៍បៃតង គឺផ្តោតលើការបង្កើនចំណាយ លើសេវាចំណាយឋានប្រព័ន្ធក៏ដូចជាការកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលបច្ចុប្បន្ន បាននិងកំពុងក្លាយជាបញ្ហានៅទូទាំងពិភពលោក។

- **ផែនទីអភិវឌ្ឍន៍បៃតងរបស់កម្ពុជាៈ** ដើម្បីឲ្យអ្នកចូលរួមក្នុងកិច្ចប្រជុំបានយល់កាន់តែច្បាស់ ឯកឧត្តម បានបង្ហាញបន្ថែមពីផែនទីអភិវឌ្ឍន៍បៃតងរបស់ប្រទេសកម្ពុជា ដោយលោកបានចង្អុលបង្ហាញចំនុចសំខាន់ៗចំនួន ០៧ រួមមានៈ
    i. ទទួលបានការគ្រប់គ្រងទឹក និងទឹកស្អាត
    ii. ទទួលបានសុវត្ថិភាពម្ហូបអាហារ (កសិកម្ម) និងផលិតផលមិនមានជាតិគីមី
    iii. ទទួលបានការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព
    iv. ទទួលបានថាមពលប្រើប្រាស់គ្រប់គ្រាន់
    v. ទទួលបានព័ត៌មាន និងចំណេះដឹង
    vi. ទទួលបានមធ្យោបាយចល័តប្រសើរជាងមុន, និង
    vii. ទទួលបានហិរញ្ញវត្ថុ និងការវិនិយោគ

នៅលើឆាកអន្តរជាតិ ប្រទេសកម្ពុជាដែលមានក្រសួងបរិស្ថានជាតំណាង បានសហការជាមួយ និងចុះអនុស្សារណៈយោគយល់ (MoU) ជាមួយវិទ្យាស្ថានអភិវឌ្ឍបៃតង (GGGI) នៃសាធារណរដ្ឋកូរ៉េកាលពីខែឧសភា ឆ្នាំ២០១១ និងសមាជិកចំនួន ១៨ ប្រទេសថែមទៀត។ ជាលទ្ធផល កម្ពុជាបានក្លាយជាប្រទេសសមាជិក GGGI ដែលជាស្ថាប័នអន្តរជាតិមួយដ៏ធំ។

នៅថ្នាក់ជាតិ, កម្ពុជាបានរៀបចំគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍន៍បៃតងពីឆ្នាំ២០១៣-២០៣០ ក្នុងគោលបំណងដើម្បីអភិវឌ្ឍសេដ្ឋកិច្ច ដោយផ្អែកលើការការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ ម្យ៉ាងទៀត គោលនយោបាយនេះ ដែលដឹកនាំដោយ ក្រសួងបរិស្ថាន មានគោលបំណងធ្វើឲ្យមានតុល្យភាពរវាងការអភិវឌ្ឍន៍សេដ្ឋកិច្ច, បរិស្ថាន, វប្បធម៌, សង្គម និងនិរន្តរភាពនៃការប្រើប្រាស់ធនធានធម្មជាតិ ដើម្បីជួយឲ្យសុខមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ។

ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍បៃតង ឆ្នាំ២០១៣-២០៣០ មានទិសដៅជម្រុញសេដ្ឋកិច្ចប្រទេសកម្ពុជា ឲ្យមានលក្ខណៈសេដ្ឋកិច្ចបៃតង ដោយផ្អែកលើការប្រើប្រាស់ធនធានធម្មជាតិឲ្យមានប្រសិទ្ធិភាព, និរន្តរភាពនៃបរិស្ថាន, ប្រជាពលរដ្ឋមានការងារល្អ, បច្ចេកទេសបៃតង, ហិរញ្ញវត្ថុ និងឥណទានមានស្ថេរភាព និងមានការវិនិយោគក្នុងន័យបរិស្ថានល្អ។ ឯកឧត្តមបានបន្ថែមថា កម្ពុជាបានសម្រេចរួចហើយ នូវគោលការណ៍ច្បាប់មួយចំនួន ពាក់ពន្ធ័នឹងការអនុវត្តន៍ការអភិវឌ្ឍន៍បៃតង។ គោលការណ៍ទាំងនោះ រួមមាន ផែនទីអភិវឌ្ឍបៃតង អនុស្សារណៈស្តីពីកិច្ចសហការអភិវឌ្ឍបៃតងរវាងរដ្ឋាភិបាលកម្ពុជា និង GGGI នៃសាធារណរដ្ឋកូរ៉េ ក្រុមប្រឹក្សាជាតិស្តីពីការអភិវឌ្ឍន៍បៃតង និងសមាជិកនៃកិច្ចព្រមព្រៀងស្តីពីការបង្កើត GGGI។ យ៉ាងណាក៏ដោយ កម្ពុជាទាមទារឲ្យមានការផ្តល់អាទិភាពតាមបណ្តាវិស័យនីមួយៗ ដើម្បីឲ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតង និងប្រកបដោយនិរន្តរភាព ហេតុនេះកម្ពុជាត្រូវផ្តោតលើសុវត្ថិភាពស្បៀង សុវត្ថិភាពនៃការប្រើប្រាស់ទឹក សុវត្ថិភាពប្រើប្រាស់ថាមពល ផលិតផលស្អាត និងគ្មានកាកសំណល់ រួមទាំងវដ្តនៃការប្រើប្រាស់ផលិតផលទៀតផ

ង។ ជាចុងបញ្ចាប់ ឯកឧត្តមបានចង្អុលបង្ហាញថា ការសម្រេចបាននូវគោលដៅសហសវត្សរបស់ប្រទេសកម្ពុជា ត្រូវអនុវត្ត និងកែលំអការអភិវឌ្ឍន៍បៃតង ដោយធ្វើសមាហរណកម្មនៃគំរូអភិវឌ្ឍបៃតងជាមួយនិងអាទិភាពទាំងបួន នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ឧទាហរណ៍ដូចជា សេដ្ឋកិច្ច បរិស្ថាន សង្គម វប្បធម៌ និងតុល្យភាពនៃការអភិវឌ្ឍន៍ ស្របតាមជំហរទាំងបួននៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងមានលក្ខណៈប្រទាក់ក្រឡាគ្នា។

## ២.២ បទពិសោធន៍នៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា - ដោយ លោកបណ្ឌិត តាន់ មុនីវណ្ណ អគ្គនាយករងនៃក្រុមហ៊ុន ម៉ុង ឬទ្ធី គ្រុប។

ប្រវត្តិមួយចំនួនរបស់ក្រុមហ៊ុនម៉ុងរិទ្ធី ត្រូវបានចែករំលែកដល់អ្នកចូលរួមក្នុងកិច្ចប្រជុំទាំងមូល ដោយលោកបានបញ្ជាក់ថា សព្វថ្ងៃក្រុមហ៊ុនមានសាខាចំនួន ១០ ទៀត ដែលជាភាគហ៊ុនរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនបានផ្តោតលើការ នាំចេញ-នាំចូល អាជីវកម្ម អចលនទ្រព្យ កសិកម្ម និងកសិ-ឧស្សាហកម្ម ជាដើម។ ក្រុមហ៊ុនក៏បានទទួលដីសម្បទានសេដ្ឋកិច្ចផងដែរពីរាជរដ្ឋាភិបាល លើផ្ទៃដីប្រមាណ ១៩៤,០០០ ហ.ត ដើម្បីធ្វើការវិនិយោគលើដំណាំដូងប្រេង ដែលក្នុងនោះ ១៥,០០០ ហ.ត សម្រាប់ដាំដើមឈើ។ ដីសម្បទានមានរយៈពេល ៧០ឆ្នាំ។ គោលបំណងនៃការវិនិយោគ គឺដើម្បីធ្វើអាជីវកម្មដូងប្រេង កសិកម្ម កសិ-អាជីវកម្ម ការកែច្នៃដូងប្រេង ក៏ដូចជាការ នាំចេញ-នាំចូល។

ក្រៅពីធ្វើអាជីវកម្ម ក្រុមហ៊ុនបានរួមចំណែកយ៉ាងច្រើនដល់ការការពារបរិស្ថាន ដូចជា ក្រុមហ៊ុនបានចំណាយមូលនិធិសម្រាប់ការពារព្រៃឈើ និងជាលទ្ធផល ព្រៃឈើជាច្រើនហិចតា ត្រូវបានការពារដោយក្រុមហ៊ុន។ នេះសបញ្ជាក់ថា ក្រុមហ៊ុនម៉ុងរិទ្ធីបានរួមចំណែកយ៉ាងច្រើនដល់ការអភិវឌ្ឍន៍បៃតងនៃប្រទេសកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ លើសពីនេះក្រុមហ៊ុនបានបង្កើតឲ្យមានជាគម្រោងផលិតកម្មជ្រូក ឬការចិញ្ចឹមជ្រូក ដើម្បីឆ្លើយតបនឹងតម្រូវការ និងការផ្គត់ផ្គង់ម្ហូបអាហារក្នុងប្រទេសកម្ពុជា។ ម្យ៉ាងទៀត ដើម្បីកាត់បន្ថយការនាំជ្រូករស់ចូលពីប្រទេសក្រៅផងដែរ។ ក្រុមហ៊ុនផលិតកម្មជ្រូកនេះ មានតួនាទីយ៉ាងសំខាន់ក្នុងឧស្សាហកម្មចិញ្ចឹមសត្វជ្រូកក្នុងប្រទេសកម្ពុជា និងក្នុងតំបន់អាស៊ី។ ចំពោះកាកសំណល់ពីការចិញ្ចឹកជ្រូក ក្រុមហ៊ុនបានកែច្នៃ និងផលិតជាជីវឧស្ម័ន និងបំលែងជាអគ្គិសនីមានកម្លាំង ១មេហ្គាវ៉ាត់។ ចំណែកជីវឧស្ម័នអាចប្រើសម្រាប់កសិកម្ម ដូចជា ស្រូវ កៅស៊ូ និងដំណាំផ្សេងទៀត។

## ២.៣ ទស្សនទានរបស់អង្គការសង្គមស៊ីវិលលើការអភិវឌ្ឍន៍បៃតង ដោយ លោក តឹក វណ្ណារ៉ា នាយកប្រតិបត្តិរង វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។




លោកបានបង្ហាញពីទស្សនទានរបស់អង្គការសង្គមស៊ីវិល តាមរយៈបទបង្ហាញ ដោយផ្តោតលើការអភិវឌ្ឍន៍និរន្តរភាព ការអភិវឌ្ឍន៍សង្គម ការការពារបរិស្ថាន និងការអភិវឌ្ឍន៍

បៃតង ដែលមានចំណាប់ផ្ដើមដោយសាធារណរដ្ឋកូរ៉េ។ បន្ទាប់ពីពន្យល់ពីទស្សនទានរួមរួចមក លោកបានលើកជាឧទា-ហរណ៍ស្ដីពីការអភិវឌ្ឍន៍បៃតងក្នុងខេត្តមណ្ឌលគិរី ដែលមានការផ្លាស់ប្ដូរយ៉ាងច្រើនក្នុងការអភិវឌ្ឍន៍ តួយ៉ាងដូចជា ផ្លាស់ប្ដូរពីព្រៃធម្មជាតិ មកជាព្រៃចំការឈើដាំ (ចំការកៅស៊ូ...) កសិ-ឧស្សាហកម្ម (ដំឡូង បារាំង ស្វាយចន្ទី ដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុនអាជីវកម្មរ៉ែ គម្រោងទំនប់វារីអគ្គិសនីនៅតំបន់ទន្លេស្រែពក ការអភិវឌ្ឍន៍ GMS ១៩៩២ និងការផ្លាស់ប្ដូរពីការធ្វើកសិកម្មពនាចរ ទៅជាធ្វើការដាំដំណាំ ដែលមានលក្ខណៈអចិន្ត្រៃយ៍។ ជាលទ្ធផលប្រជាពលរដ្ឋក្នុងខេត្តមណ្ឌលគិរី ជួបការលំបាកច្រើន ប៉ុន្តែក៏មានកាលានុវត្តភាពផងដែរ រួមមានៈ

- កាលានុវត្តភាពៈ មានការងារបន្ថែម, បានកើនចំណេះដឹង, ការទំនាក់ទំនង និងសេវាសង្គមមានការកើនឡើង និងហេដ្ឋារចនាសម្ព័ន្ធមានភាពប្រសើរឡើង។
- ការផ្លាស់ប្ដូរៈ ចំណេះដឹងនៅមានកម្រិត, ពុំមានបទពិសោធន៍ (ជំនាញ និងបទពិសោធន៍បច្ចេកទេស) មានការប្រកួតប្រជែងការងារ, មានការផ្លាស់ប្ដូរវប្បធម៌ និងមានសម្ពាធលើការប្រើប្រាស់ធនធានធម្មជាតិ ក៏ដូចជាការថយចុះរបស់វា ។

ចុងបញ្ចប់ លោកបានចែករំលែកផងដែរ ជូនអ្នកចូលរួមអំពី លទ្ធផលនៃការចូលរួមប្រជុំកាលពីថ្ងៃទី៦ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២ នៅ កោះចេយូរ សាធារណរដ្ឋកូរ៉េ ដោយមានអ្នកចូលរួមប្រមាណ ១០,០០០នាក់ ក្នុងនោះ ជំនាញការចំនួន ៥,០០០នាក់ មកពី ១៥៣ប្រទេស និងមានសកម្មភាពចំនួន ៦០០ ដើម្បីគាំទ្រដល់កិច្ចប្រជុំនេះ។ កិច្ចប្រជុំមានគោលបំណងចែករំលែកព័ត៌មាន និងបទពិសោធន៍ស្ដីពីការអភិរក្ស និងបង្កើនយន្តការដើម្បីកែលំអនាពេលអនាគត។ ខាងក្រោមនេះជាប្រធានបទសំខាន់ដែលបានពិភាក្សា និងសម្រេចៈ

- ធម្មជាតិ ព្រៃជាពលរដ្ឋ និងអភិបាលកិច្ច
- ធម្មជាតិ និងការអភិវឌ្ឍន៍
- ធម្មជាតិ និង ម្ហូបអាហារ
- ធម្មជាតិ និងអាកាសធាតុ

**ការពិភាក្សាទូទៅ:**



-

- **លោក ប៉ែន សុខុន** នាយកអង្គការ NREDO មកពីខេត្តស្ទឹងត្រែងៈ សំណូមពរបន្ថែមលើផែនការអភិវឌ្ឍន៍បៃតង ខ្ញុំគិតថា អាទិភាពដែលបានលើកឡើងពិតជាល្អ ប៉ុន្តែសំណូមពរបន្ថែមមួយចំនុចទៀត គឺ ការទទួលបានព័ត៌មាន ព្រោះវាសំខាន់ណាស់សម្រាប់ធ្វើការសម្រេចចិត្ត។
- **លោកស្រី កែវ ណាវណ្ណ** មកពីអង្គការ **AFSC** បានសួរសំណួរទៅ ឯកឧត្តមបណ្ឌិត ឈុន វណ្ណៈពាក់ព័ន្ធនឹងចង្ក្រានប្រើពន្លឺព្រះអាទិត្យថា តើរដ្ឋាភិបាលពិតជាមាន និងចែកជូនដល់ប្រជាពលរដ្ឋទាំងនៅជនបទ និងជាយក្រុងមែនទេ ព្រោះវាមានសារៈសំខាន់ និងមានការចាប់អារម្មណ៍ពីប្រជាពលរដ្ឋយ៉ាងច្រើន។
- **លោក ឯក វីសារៈយុន** ប្រធានអង្គការ CMFE (KPT) មកពីខេត្តកំពង់ធំៈ ខ្ញុំបានឃើញតាមរយៈសារព័ត៌មាន (កាសែត) ថា កម្ពុជាជាប្រទេសឧក្រិដ្ឋជនព្រៃឈើ ហើយក្នុងនាមរដ្ឋាភិបាល អង្គការសង្គមស៊ីវិល វិស័យឯកជន ថាតើយើងត្រូវធ្វើដូចម្តេច ដើម្បីទប់ស្កាត់ការបំផ្លាញព្រៃឈើក្នុងប្រទេសកម្ពុជា។ ម្យ៉ាងទៀត ខ្ញុំសំណូមពរ និងប្រសិនបើអាច គួរលុបក្រុមហ៊ុនព្រៃសម្បទាន ដែលអាចជាគំរូដូចវិស័យជលផល ដែលបានលុបឡូត៍នេសាទផងដែរ។

**សម្រាយបញ្ជាក់**: ឯកឧត្តមបណ្ឌិត ឈុន វណ្ណៈ, ខ្ញុំគិតថា ការទទួលបានព័ត៌មាន និងចំណេះដឹង បានដាក់បញ្ចូលក្នុងផែនការអាទិភាពរួចហើយ និងម្យ៉ាងទៀត គឺពាក់ព័ន្ធនឹងការប្តេជ្ញាចិត្តរបស់ប្រទេសនីមួយៗ និងប្រទេសកម្ពុជាខ្លួនឯង ត្រូវតែប្តេជ្ញាអនុវត្តគ្រប់កិច្ចការទាំងអស់។ ចំណែកឯចង្ក្រាន គឺជាគម្រោងសាកល្បង ដោយមានការគាំទ្រពីប្រទេសជិតខាង និងផ្តល់មូលនិធិពី JJI។ គម្រោងនេះមានទីតាំងនៅក្នុងស្រុកសំរោង ខេត្តតាកែវ។ យ៉ាងណាក៏ដោយតម្លៃនៃបច្ចេកវិទ្យានេះ មានតម្លៃខ្លាំងណាស់ និងមានតែវិស័យឯកជនទេ ដែលអាចអនុវត្តបាន។

## ២.៤ បទបង្ហាញអំពីដំណើរការពិគ្រោះយោបល់នៃអង្គការសង្គមស៊ីវិល លើសេចក្តីព្រៀងច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដោយ លោក ឈិត សំអាត នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។



លោកនាយកបានសង្ខេបខ្លី អំពីខ្លឹមសារនៃច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន ដែល បានកើតឡើងតាំងពីយូរណាស់មកហើយ ហើយច្បាប់នេះផ្តោតជាសំខាន់លើការប៉ះពាល់លើមនុស្ស (ប្រជាពលរដ្ឋ) និងរបាយការណ៍ផលប៉ះពាល់បរិស្ថាន។ សេចក្តីព្រាងច្បាប់នេះមានចំនួន ១៨ជំពូក និង ៨១ មាត្រា ក្នុងគោលបំណងធានាថា សេចក្តីព្រាងច្បាប់នេះមានលក្ខណៈស្របតាមច្បាប់ត្រឹមត្រូវ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានជាអប្បបរមាលើប្រជាពលរដ្ឋ និងបរិស្ថាន។ ការពិគ្រោះយោបល់ជាសាធារណៈត្រូវបានរៀបចំ និងផ្តល់យោបល់បន្ថែមតាមរយៈចំនុចសំខាន់ៗមួយចំនួន ដូចខាងក្រោមៈ

- ណែនាំអំពីគោលការណ៍ការពារបរិស្ថាន ដូចជា គោលការណ៍សម្រាប់ត្រៀមបង្ការជាមុន
- ដំណើរការនៃការត្រួតពិនិត្យបរិស្ថានដំបូង និងដំណើរការនៃការព្រមព្រៀងការការពារបរិស្ថាន

- សុពលភាពនៃវិញ្ញាបនបត្រឯកភាពចំពោះរបាយការណ៍ EIA មិនឲ្យលើសពី៥ឆ្នាំ (*ពីមុនមិនមានកំណត់ពេលវេលានោះទេ*) មាត្រា ២២។
- លើកទឹកចិត្តឲ្យមានការចូលរួមជាសាធារណៈ រួមទាំងការប្រកាសជាសាធារណៈផងដែរ នូវរបាយការណ៍ EIA។
- មានដាក់បញ្ចូលក្របខណ្ឌ EIA ឆ្លងដែន
- ការតាមដាន EIA ដោយអ្នកខាងក្រៅ (សវនករបរិស្ថានខាងក្រៅ)
- អ្នកស្នើគម្រោងចាំបាច់ត្រូវចូលរួមចំនួន **១ ភាគរយ នៃថវិកាគម្រោង** ដើម្បីប្រើប្រាស់សម្រាប់មូលនិធិបរិស្ថាន និងសង្គម។
- មានវិធានការតឹងរឹង (ក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទណ្ឌ) ក្នុងការជម្រុញការអនុវត្តច្បាប់នេះ
- មានបញ្ចូលគោលការណ៍ ការព្រមព្រៀងដោយសេរីជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC) មាត្រា ២៥។
- មានដាក់បញ្ចូលសិទ្ធិចូលរួម ទទួលបានព័ត៌មាន និងយុត្តិធម៌
- មានដាក់បញ្ចូលបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងច្បាប់

**មតិយោបល់ដើម្បីកែសម្រួលខ្លឹមសានៃច្បាប់**

- ការចូលរួមពិគ្រោះយោបល់ជាសាធារណៈ គួរតែធ្វើឲ្យបានច្រើនកន្លែង និងពេញលេញ ជាពិសេស ការចូលរួមសម្រេចចិត្ត។
- ការប្រកាសជាសាធារណៈអំពីគម្រោង និងរបាយការណ៍ EIA គួរធ្វើឡើងឲ្យបានទូលំទូលាយ មិនត្រឹមតែបង្ហោះតាមគេហទំព័រ ប៉ុន្តែថែមទាំងទីកន្លែងសាធារណៈ និងតំបន់ដែលនឹងរងផលប៉ះពាល់ពីគម្រោង។
- បង្កើនពី ៦០ថ្ងៃ ទៅ ៩០ថ្ងៃ នៃថ្ងៃធ្វើការសម្រាប់ការពិនិត្យរបាយការណ៍ និងការពិគ្រោះយោបល់ជាសាធារណៈ (មាត្រា ១៦)។
- តួនាទី និងភារកិច្ច ពុំមានប្រជាពលរដ្ឋឈរជាដើមបណ្ដឹង
- ករណីទោសទណ្ឌមួយចំនួនអាចជាន់គ្នានឹងច្បាប់ដែលមានចែងរួចហើយ
- (ក្រមព្រហ្មទណ្ឌ និងរដ្ឋប្បវេណី) គួរតែមានការពិនិត្យទៅលើច្បាប់ដែលពាក់ព័ន្ធផ្សេងៗ
- ការផ្សាយតាមវែបសាយមានការលំបាកសម្រាប់សហគមន៍មូលដ្ឋាន និង អាជ្ញាធរ
- មិនបានស្ទាបស្ទង់ជាមូលដ្ឋានជាមួយអ្នកពាក់ព័ន្ធ សហគមន៍ មុនពេលបង្កើតច្បាប់នេះ
- ការសរសេរមានភាពស្មុគ្រស្មាញ ជាពិសេស គោលការណ៍នៃការចូលរួម
- លទ្ធភាពស្វែងរកយុត្តិធម៌ សិទ្ធិក្នុងការចូលរួម សិទ្ធិទទួលបានព័ត៌មានល្អ ប៉ុន្តែ អ្វីដែលព្រួយបារម្ភ គឺការមិនទទួលយកគំនិតសហគមន៍។
- ច្បាប់នេះ គួរចូលរួមពីថ្នាក់តំបន់ និងប្រទេសជិតខាង ក្នុងការចូលរួមពិគ្រោះយោបល់ ដើម្បីជៀសវាងការជាន់ច្បាប់អន្តរជាតិ និងតំបន់។
- គួរតែរំលេចឲ្យឃើញពីភាពជាដៃគូរវាងអង្គការសង្គមស៊ីវិល

- រដ្ឋាភិបាល វិស័យឯកជន សហគមន៍ ក្នុងករណីបន្ទាន់ណាមួយ
- ពេលវេលាពិនិត្យរបាយការណ៍ខ្លីសម្រាប់សង្គមស៊ីវិលមានរយៈពេលខ្លី
- របាយការណ៍ខ្លះគឺគ្រាន់តែថតចម្លងតៗគ្នា
- របាយការណ៍ដែលបានអនុម័ត ពុំដែលចែករំលែកដល់អង្គការសង្គមស៊ីវិល និងសាធារណៈជន។
- សមាជិកអន្តរក្រសួង ពុំមានពេលគ្រប់គ្រាន់ពិនិត្យបច្ចេកទេស លើផែនការបន្ធូបន្ថយផលប៉ះពាល់ និងផែនការគ្រប់គ្រងបរិស្ថាន។
- សំណើរបស់សហគមន៍ពុំមានកត់ត្រាដោយក្រុមហ៊ុនទីប្រឹក្សានៅក្នុងរបាយការណ៍ឲ្យបានពេញលេញ។
- សំណើ និងបញ្ហានានារបស់សហគមន៍ មិនបានយកទៅពិភាក្សាក្នុងកិច្ចប្រជុំអន្តរក្រសួង

**សំណូមពរដើម្បីកែលំអរបាយការណ៍ EIA**

- បង្កើនពេលវេលាពិនិត្យលើរបាយការណ៍ EIA យ៉ាងហោចណាស់ ៩០ថ្ងៃ នៃថ្ងៃធ្វើការ
- រាល់មតិយោបល់របស់សហគមន៍ត្រូវកត់ត្រា និងយកទៅពិភាក្សានៅថ្នាក់អន្តរក្រសួង
- រាល់របាយការណ៍បញ្ចប់ ត្រូវចែកជូនជាសារធារណៈ ជាពិសេស ថ្នាក់មូលដ្ឋាន
- ជៀសវាងរបាយការណ៍ចម្លងតៗគ្នា ហើយពុំបានសិក្សាស៊ីជម្រៅ
- ការតាមដានការអនុវត្តផែនការគួរធ្វើជាទៀងទាត់ និងតឹងរឹង
- ជៀសវាងដាច់ខាតគម្រោងដែលអនុវត្តដោយគ្មានរបាយការណ៍ EIA
- សូមឲ្យមានការចូលរួមពីសារធារណៈជនឲ្យបានពេញលេញ នៅគ្រប់ដំណាក់កាលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

**ផែនការបន្ត**

- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា នឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិរយៈពេល ២ថ្ងៃ គឺថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ២០១៣ នេះ ដោយមានការចូលរួមពីអង្គការជាតិ អន្តរជាតិ ដៃគូរអភិវឌ្ឍន៍ តំណាងសហគមន៍មូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ។
- បន្តគៀងគរអ្នកជំនាញការជាតិ និងអន្តរជាតិ ដើម្បីជួយពិនិត្យ និងផ្តល់យោបល់
- មតិយោបល់ទាំងអស់នឹងផ្ញើជូនក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងកែសម្រួល
- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងសមាជិក សូមស្វាគមន៍ និងរីករាយ ក្នុងការជួយដល់រាជរដ្ឋាភិបាល ដើម្បីពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ក្នុងន័យកែលម្អច្បាប់នេះឲ្យមានខ្លឹមសារកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធិភាពសម្រាប់ការអនុវត្ត។

**២.៥ បទពិសោធន៍នៃសហគមន៍រងគ្រោះចំពោះដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយ លោកស្រី ញឹម ប៉ូរ៉ានី តំណាងសហគមន៍ខេត្តរតនគីរីៈ**



យើងខ្ញុំជាសហគមន៍ មានការបារម្ភយ៉ាងខ្លាំងថា បើទំនប់សាងសង់នៅប៉ែកខាងលើនោះ នឹង មានផលប៉ះពាល់យ៉ាងខ្លាំងដល់ប្រទេសរបស់យើងខ្ញុំ។ តែបើសិនជានឹងសាងសង់ក្នុងប្រទេសកម្ពុជា វិញនោះ ថាតើវានឹងយ៉ាងណាដែរ អស់លោក-លោកស្រី អាចនឹងស្រមើស្រម៉ៃ។ យើងខ្ញុំសំណូមពរដល់ រដ្ឋាភិបាល ប្រសិនបើអាចបញ្ឈប់ការសាងសង់ ឬពន្យារការសាងសង់បាន ជាការប្រសើរ ឬប្រសិនបើរដ្ឋាភិបាលអាចសង់កន្លែងផ្សេង។ ជាឧទាហរណ៍ ទំនប់យ៉ាលី ពិតជាមានផលប៉ះពាល់លើជីវភាពរបស់យើងខ្ញុំ ដូចជា លើសត្វពាហនៈ ការបាត់បង់ផ្ទះសម្បែង ជាដើម។ ពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ច យើងខ្ញុំមិនច្បាស់លាស់នោះទេ ថាតើមានការទទួលស្គាល់ដែរឬទេ ព្រោះថា ប្រជាពលរដ្ឋមិនបានទទួលព័ត៌មាន ហើយយើងខ្ញុំមិនមានដីសម្រាប់ពង្រីកឡើយ។ ទឹកជំនន់ឡើងលិចពួកយើងរៀងរាល់ឆ្នាំ ហើយយើងមានការព្រួយបារម្ភយ៉ាងខ្លាំងនាពេលអនាគត់ ដោយយើងកំពុងជួបប្រទះកន្លងមកនេះ។ ចំណែកពួកយើងនៅប៉ែកខាងលើទំនប់មិនបានទទួលសំណងអ្វីសោះ គឺបានតែអ្នករស់នៅក្នុងតំបន់ទំនប់ប៉ុណ្ណោះ។ ប្រជាពលរដ្ឋមានការសប្បាយចិត្តចំពោះការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ប៉ុន្តែសូមឲ្យរដ្ឋាភិបាលពិនិត្យមើលការព្រួយបារម្ភរបស់យើងខ្ញុំផងដែរ។ ចំពោះប្រជាពលរដ្ឋនៅទីក្រុង មិនបានជួបប្រទះការលំបាលដូចពួកយើងឡើយ សូមមេត្តារដ្ឋាភិបាលអាចមានជម្រើសផ្សេងវិញ។

**ការពិភាក្សារួម:**

- **សំណួរ: លោក កង សំណាង** អ្នកសម្របសម្រួលនៃអង្គការ KKKHRDA មកពីខេត្តកំពង់ស្ពឺ: តើអ្នកមានវិធីសាស្រ្តអ្វីខ្លះ ក្នុងការទាមទារ ឬ តស៊ូមតិ ក្នុងករណីនៃការសាងសង់ទំនប់វារីអគ្គិសនី?
- **ចម្លើយ:** យើងមានសេចក្តីថ្លែងការណ៍រួម ដូចដែលបានពិភាក្សាគ្នា ហើយបានផ្ញើទៅរដ្ឋសភាជាតិរួចហើយអំពីបញ្ហានៃការរងផលប៉ះពាល់ពីការសាងសង់ទំនប់។ យើងបានរៀបចំវេទិកានៅថ្នាក់ភូមិ ហើយបានចេញសេចក្តីថ្លែងការណ៍ទៅរដ្ឋសភាជាតិ ប៉ុន្តែពុំមានការឆ្លើយតបនៅឡើយទេ។
- **សំណួរ: លោក ប៉ែន សុខុន** នាយកនៃអង្គការ NREDO មកពីខេត្តស្ទឹងត្រែង: តើអ្នកមានជម្រើសអ្វី បើទំនប់មិនបានសាងសង់?
- **ចម្លើយ:** ខ្ញុំគិតថា ប្រើពន្លឺព្រះអាទិត្យ ទំនប់ខ្នាតតូច ដោយមិនមានផលប៉ះពាល់ ឬប៉ះពាល់តិចតួច។ ប្រសិនបើមានការសាងសង់ ត្រូវមានសំណងសមហេតុផល និងតម្លៃសមរម្យ។

## ២.៦ បច្ចុប្បន្នកម្មព័ត៌មាននៃដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ (NSDP):



**លោកស្រី ចាន់ សុខយ៉េង** ប្រធានកម្មវិធីបញ្ហាអភិវឌ្ឍន៍ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានធ្វើបច្ចុប្បន្នភាពនៃដំណើរការផ្តល់យោបល់របស់អង្គការសង្គមស៊ីវិលស្តីពីផែនការយុទ្ធសាស្ត្រអភិ-វឌ្ឍជាតិ ឆ្នាំ២០១៤-២០១៨ និងផែនការរៀបចំវេទិកានយោបាយ នាពេលអនាគត។ លោកស្រីក៍បានចែករំលែកផងដែរ អំពីកាលបរិច្ឆេទផុតកំណត់ក្នុងដំណើរការនេះ និងអំពីរបៀបដែលសង្គមស៊ីវិលត្រូវចូលរួមក្នុងការផ្តល់យោបល់នេះ។

**មូលហេតុអង្គការសង្គមស៊ីវិលត្រូវចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ២០១៤-២០១៨:**

- អង្គការសង្គមស៊ីវិលជាម្ចាស់ប្រទេស ត្រូវតែយល់ដឹងពីគោលនយោបាលជាតិ ដែលមានរដ្ឋាភិបាលជាម្ចាស់ផងដែរ។
- ការចូលរួមពីសង្គមស៊ីវិល នឹងមានការចែករំលែកព័ត៌មាន ពិគ្រោះយោបល់ កិច្ចសហការ ក្នុងការអភិវឌ្ឍន៍កម្មវិធី និងមានការវាយតម្លៃដោយមានការចូលរួម។ ដូច្នេះអង្គការសង្គមស៊ីវិល មានតួនាទីសំខាន់ក្នុងការចូលរួមរៀបចំ**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ឆ្នាំ ២០១៤-២០១៨។**

**ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ឆ្នាំ ២០១៤-២០១៨:**

- អង្គការសង្គមស៊ីវិល ត្រូវធ្វើការទំនាក់ទំនងផ្តល់ធាតុចូលដោយផ្ទាល់ ដល់អន្តរក្រសួង និងដៃគូរអភិ-វឌ្ឍ តាមរយៈការពិភាក្សាជាមួយក្រុមការងារបច្ចេកទេស ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ឆ្នាំ២០១៤-២០១៨។
- អង្គការសង្គមស៊ីវិលត្រូវចូលរួមតាមវិស័យរបស់ខ្លួន ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) ឆ្នាំ២០១៤-២០១៨ ហើយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ជាអ្នកសម្របសម្រួល តាមរយៈកម្មវិធីបញ្ហានៃការអភិវឌ្ឍន៍ ដើម្បីផ្តល់ជាយោបល់រួមដល់រាជរដ្ឋាភិបាល ពិចារណាមុននឹងធ្វើការសម្រេចចិត្ត។
- ចំណុចសំខាន់ដែលអង្គការសង្គមស៊ីវិលមាន គួរតែដាក់បញ្ចូល រួមមានៈ
  - o ទស្សនៈរបស់អង្គការសង្គមស៊ីវិលស្តីពីមាតិកា និងវឌ្ឍនភាពនៃបច្ចុប្បន្នភាព NSDP ឆ្នាំ២០០៩-២០១៣;
  - o ចំនុចសំខាន់ៗដែលបង្ហាញពីការចូលរួម និងតួនាទីចាំបាច់របស់សង្គមស៊ីវិល

## ៣. សេចក្តីសង្ខេប និងការបិទអង្គប្រជុំ

ជាទីបញ្ចប់ **លោក ស៊ុន យូ៉ា** ប្រធានអង្គប្រជុំ បានសង្ខេប និងធ្វើសេចក្តីសន្និដ្ឋាននៃកិច្ចប្រជុំ ដោយបានលើកឡើងថា យើងបានពិភាក្សាលើប្រធានបទចំនួនបីសំខាន់ៗ ដែលមានការចូលរួមយ៉ាងផុលផុសពីអ្នកចូលរួមទាំងអស់។ ក្នុងកិច្ចប្រជុំនេះ យើងមានវាគ្មិនចំនួនបីរូបសំខាន់ គឺ ឯកឧត្តមបណ្ឌិត ឈុន វណ្ណៈ បានធ្វើបទបង្ហាញអំពីគោលនយោបាលជាតិស្តីពីការអភិវឌ្ឍន៍បៃតង និងផែនការយុទ្ធសាស្ត្រ ឆ្នាំ២០១៣-២០៣០ លោកបណ្ឌិត តាន់ មុនីវណ្ណ បានចែករំលែកពីបទពិសោធន៍កម្មវិធីអភិវឌ្ឍបៃតងក្នុងប្រទេសកម្ពុជា រួមមាន ការព្រួយបារម្ភ និងសំណូមពរសម្រាប់ការអភិរក្ស។ លើសពីនេះទៀត ចំនុចសំខាន់ៗមួយចំនួន ដែលជាលទ្ធផលនៃសមាជ ដែលបានចូលរួមដោយ លោក តឹក វណ្ណារ៉ា ក៏បានចែករំលែកផងដែរដល់អ្នកចូលរួម។ ខណៈនោះអង្គប្រជុំក៏បានទទួលព័ត៌មានផងដែរអំពីផលប៉ះពាល់នៃការសាងសង់ទំនប់វារីអគ្គិសនី ជាពិសេស ការប៉ះពាល់លើសហគមន៍ផ្នែកខាងក្រោម និងខាងលើខ្សែទឹក។ ជាចុងក្រោយ លោក ឈិត សំអាត នាយកប្រត្តិបត្តិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា បានចែករំលែកអំពីដំណើរការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ EIA។ លោក ស៊ុន យូ៉ា បានសំដែងនូវអំណរគុណ និងគោរពជូនពរដល់អ្នកចូលរួម សូមមានសំណាងល្អ និងជោគជ័យគ្រប់ភារកិច្ច និងប្រកាសបិទអង្គប្រជុំ៕

---ចប់---